ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០០៣/១៦ ក.ប/ស.ណ.ន

# សេចក្តីណែនាំអនុវត្ត
# ស្តីពី
# ការពង្រឹងបទប្បញ្ញត្តិមួយចំនួនសម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន ដែលជាគ្រឹះស្ថាន ស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ

កន្លងមក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានពិនិត្យឃើញថា ទីភ្នាក់ងារជ្រើសរើសឯកជនមួយចំនួន ដែលជាគ្រឹះស្ថានស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ បានអនុវត្តកាន់តែល្អប្រសើរឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ និងបានចូលរួមក្នុងការកែលម្អ ការលើកកម្ពស់លក្ខខណ្ឌការងារ និងភាពសុខដុមនៃទំនាក់ទំនងវិជ្ជាជីវៈ ក៏ដូចជាសុវត្ថិភាពការងារ បានល្អប្រសើរ ដែលសហគមជាតិ និងអន្តរជាតិបានទទួលស្គាល់។

ទន្ទឹមនឹងនេះ ក្រសួងក៏បានពិនិត្យឃើញផងដែរថា នៅមានគ្រឹះស្ថានមួយចំនួនផងដែរ ដែលនៅមិនទាន់បានអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ទាក់ទងទៅនឹងបែបបទស្តីពីសហគ្រាស គ្រឹះស្ថាន និងនីតិវិធី ក្នុងការដំណើរការនៅឡើយ ជាពិសេសទីភ្នាក់ងារជ្រើសរើសឯកជនទទួលបន្ទុកការជ្រើសរើស បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស ដែលទាមទារនូវការតាមឃ្លាំមើល ការដាស់តឿនក្រើនរំលឹក និង ធ្វើការកែតម្រូវរាល់បាតុភាពខុសឆ្គងជាបន្តបន្ទាប់។ បន្ថែមទៅនឹងស្ថានភាពនៃការអនុវត្តបទប្បញ្ញត្តិច្បាប់ស្តីពីការងារ ក្រសួងក៏បានពិនិត្យ ឃើញផងដែរថា ទីភ្នាក់ងារជ្រើសរើសឯកជនមួយចំនួនធំ ក៏នៅមិនទាន់អនុវត្តបានល្អប្រសើរនៅឡើយ នូវបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ១៩០ អនក្រ. បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពី ការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន ក៏ដូចជាប្រកាសចំនួន៨ ដែលក្រសួងបានចេញសម្រាប់ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តនូវបទប្បញ្ញត្តិនៃច្បាប់ ដែលមានជាធរមាន និងបទប្បញ្ញត្តិនៃច្បាប់មួយចំនួនទៀតផងដែរ ចំពោះស្ថានភាពដូចបានសង្កេតឃើញខាងលើនេះ និងក្នុងគោលដៅលើកកម្ពស់ការពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវារកការឱ្យធ្វើនៅបរទេសក៏ដូចជាការពង្រឹង ការលើកកម្ពស់ និងការការពារសិទ្ធិពលករទេសន្តរប្រវេសន៍កម្ពុជា ក៏ដូចជាការលុបបំបាត់ បាតុភូតអសកម្មមួយចំនួន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការណែនាំ និងរំលឹកទីភ្នាក់ងារជ្រើសរើសឯកជនឱ្យអនុវត្តត្រឹមត្រូវតាមចំណុចមួយចំនួនដូចតទៅ:-

១-ត្រូវរៀបចំឱ្យមានទីចាត់ការ ដែលមានអាសយដ្ឋានច្បាស់លាស់ មានបុគ្គលិកបម្រើការងារ មានសម្ភារៈការិយាល័យ មធ្យោបាយទំនាក់ទំនង និងមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាន់។

២-ត្រូវរៀបចំឱ្យមានមជ្ឈមណ្ឌលណែនាំតម្រង់ទិស ដែលមានទំហំសមស្រប មានអគារគ្រប់គ្រាន់



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

សម្រាប់ការងារបំប៉នមុខជំនាញ មានកន្លែងស្នាក់នៅហូបចុករបស់ពលករ ធានាបាននូវសុខភាព អនាម័យ និងមានសុវត្ថិភាពល្អ ព្រមទាំងមានបទបញ្ជាផ្ទៃក្នុងសម្រាប់មជ្ឈមណ្ឌល។

៣-ត្រូវរៀបចំឱ្យមានបែបបទសហគ្រាស គ្រឹះស្ថាន ស្របតាមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ រួមមាន:-

- សេចក្តីប្រកាសជូនដំណឹងបើកគ្រឹះស្ថាន
- សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន
- សៀវភៅបើកប្រាក់ ឬបញ្ជីបើកប្រាក់សម្រាប់កម្មករនិយោជិត
- បទបញ្ជាផ្ទៃក្នុងប្រចាំគ្រឹះស្ថាន
- សៀវភៅការងារ និងប័ណ្ណការងារ សម្រាប់កម្មករនិយោជិតខ្មែរ
- សៀវភៅការងារ និងប័ណ្ណការងារ សម្រាប់ជនបរទេស។

៤-ត្រូវរៀបចំឱ្យមានការចុះបញ្ជិកា និងការបង់ប្រាក់ភាគទាននៃបេឡាជាតិរបបសន្តិសុខសង្គម ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

៥-ត្រូវមានតំណាងអចិន្ត្រៃយ៍របស់ខ្លួនប្រចាំនៅប្រទេសទទួលពលករ ដោយបុគ្គលិកនៃតំណាងអចិន្ត្រៃយ៍ម្នាក់ៗ ត្រូវមានចំណេះដឹងផ្លូវច្បាប់របស់ប្រទេសទទួលពលករឱ្យបានសមស្រប សម្រាប់ជួយបង្កា ជួយការពារ និងចូលរួមដោះស្រាយរាល់បញ្ហា ដែលអាចនឹងកើតមាន ឬកើតមានឡើងចំពោះពលករ។

៦-ត្រូវរៀបចំឱ្យមាន និងរក្សាទុកឱ្យបានត្រឹមត្រូវ នូវឯកសារ និងទិន្នន័យរបស់ពលករមួយចំនួន ដូចជា:-

- សៀវភៅបន្ទុក និងការអនុវត្តរបបកត់ត្រាក្នុងសៀវភៅបន្ទុកឱ្យបានត្រឹមត្រូវ និងទៀងទាត់
- ត្រូវរក្សាទុកទិន្នន័យស្ថិតិ និងព័ត៌មានពលករ ដែលបានបញ្ជូនទៅប្រទេសទទួលពលករមួយលើកៗ
- ត្រូវរក្សាទុកទិន្នន័យស្ថិតិ និងព័ត៌មានពលករ ដែលបានដាក់ឱ្យធ្វើការដល់ទីកន្លែងធ្វើការមួយលើកៗ
- ត្រូវរក្សាទុកទិន្នន័យស្ថិតិ និងព័ត៌មានពលករដែលបានវិលត្រឡប់មកវិញមុនការបញ្ចប់កិច្ចសន្យាការងារ
- ត្រូវរក្សាទុកទិន្នន័យស្ថិតិ និងព័ត៌មានពលករ ដែលបានបន្តកិច្ចសន្យាថ្មីឡើងវិញ
- ត្រូវរក្សាទុកទិន្នន័យស្ថិតិ និងព័ត៌មានពលករ ដែលពុំបានបន្តកិច្ចសន្យាការងារ
- ត្រូវរក្សាទុកទិន្នន័យស្ថិតិ និងព័ត៌មានពលករ ដែលអត់ការងារធ្វើ ហើយត្រូវបញ្ជូនវិលត្រឡប់មកវិញ
- ត្រូវរក្សាទុកទិន្នន័យស្ថិតិ និងព័ត៌មានពលករ ដែលបានបាត់ខ្លួន
- ត្រូវរក្សាទុកទិន្នន័យស្ថិតិ និងព័ត៌មានពលករ ដែលបានទទួលមរណៈភាព
- ត្រូវរក្សាទុកទិន្នន័យស្ថិតិ និងព័ត៌មានពលករ ដែលបានធ្វើមាតុភូមិនិវត្តន៍ដោយបានបញ្ចប់កិច្ចសន្យាការងារ។

៧-ការរៀបចំឱ្យមាន និងរក្សាទុកឱ្យបានល្អ គង់វង្សនូវឯកសារ និងកិច្ចសន្យា ដូចខាងក្រោម៖

- ត្រូវមាន និងរក្សាទុកនូវកិច្ចព្រមព្រៀង ឬ អនុស្សរណៈនៃការយោគយល់គ្នា រវាងទីភ្នាក់ងារជ្រើសរើសឯកជន នៅកម្ពុជា និងទីភ្នាក់ងារជ្រើសរើសឯកជន ដែលជាដៃគូ នៅបរទេសទទួលពលករ ។

- ត្រូវមានកិច្ចសន្យាសេវាកម្មការឱ្យធ្វើ រវាងទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ជាមួយពលករ

- ត្រូវមានកិច្ចសន្យាការងារ រវាងពលករ និងនិយោជកនៅឯបរទេស ដែលជាអ្នកជួលពលករឱ្យធ្វើការ។

៨-ទីភ្នាក់ងារជ្រើសរើសឯកជននីមួយៗ មិនអាចជួល ឬចុះកិច្ចសន្យាបន្ត ឬលក់ផ្នែកណាមួយនៃប្រកាសរបស់ខ្លួនទៅឱ្យបុគ្គល ឬក្រុមហ៊ុនណាមួយផ្សេងទៀតបានឡើយ។ ទង្វើនេះ អាចប្រឈមនឹងការផ្តន្ទាទោសតាមច្បាប់ជាធរមាន។

៩-ក្នុងការបញ្ជូនពលករមួយលើកៗ ទៅដាក់ឱ្យធ្វើការដល់ទីកន្លែង តាមកិច្ចសន្យាសេវាកម្មការឱ្យធ្វើ និងកិច្ចសន្យាការងារ ទីភ្នាក់ងារជ្រើសរើសឯកជននីមួយៗ ត្រូវមានសេចក្តីបញ្ជាក់របស់នាយកដ្ឋានមុខរបរ និងហត្ថពលកម្មថា ពលករទាំងអស់សុទ្ធតែទទួលបានការណែនាំតម្រង់ទិស មានឯកសារគ្រប់គ្រាន់បញ្ជាក់អំពីភាពស្របច្បាប់របស់ពលករ។

១០-រាល់ការផ្សព្វផ្សាយជាសាធារណៈអំពីការជ្រើសរើសពលករ ទៅធ្វើការនៅបរទេស ត្រូវមានការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាមុនសិន ទើបទីភ្នាក់ងារជ្រើសរើសឯកជនអាចចាត់ចែងសម្រាប់ធ្វើការផ្សព្វផ្សាយបាន។

១១-គ្រប់ភ្នាក់ងារជ្រើសរើសទាំងអស់ចុះធ្វើការជ្រើសរើស និងផ្សព្វផ្សាយរាល់ព័ត៌មានទាក់ទងដល់ពលករខ្មែរទៅធ្វើការនៅបរទេស ត្រូវមានឯកសណ្ឋាន ស្លាកឈ្មោះ ស្លាកសញ្ញារបស់ទីភ្នាក់ងារជ្រើសរើសឯកជន ព្រមទាំងមានលិខិតឧទ្ទេសនាមដែលចុះហត្ថលេខាដោយ អគ្គនាយកដ្ឋានការងារ និងសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា ហើយត្រូវមានកិច្ចសហការល្អពីអាជ្ញាធរដែនដីផងដែរ។

១២-ទីភ្នាក់ងារជ្រើសរើសឯកជននីមួយៗ ត្រូវប្រើប្រាស់វិក្កយបត្រស្តង់ដារ ដែលកំណត់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានគំរូឧបសម្ព័ន្ធជូនជាប់ជាមួយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់បំផុតតាមនីតិវិធីនៃច្បាប់ ដោយគិតចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦នេះតទៅ ចំពោះទីភ្នាក់ងារជ្រើសរើសឯកជនណា ដែលមិនអនុវត្តតាមសេចក្តីណែនាំអនុវត្តខាងលើនេះ។

ទទួលបានសេចក្តីណែនាំអនុវត្តនេះ សូមអស់លោក លោកស្រី ជាប្រធានទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់មេត្តាអនុវត្តឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៦

រដ្ឋមន្ត្រី

អ៊ិត សំហេង

# គំរូវិក្កយបត្រសម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន

Logo
ក្រុមហ៊ុន

## ក្រុមហ៊ុន អ៊ឹង រិទ្ធី ខូ អិលធីឌី

Ung Rithy Co., Ltd

អាសយដ្ឋាន: អគារលេខ០៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
Adress: #03, Russian Blvd, Sangkat Teuk Laak 1, KhanTuol Kork, PhnomPenh
ទូរស័ព្ទលេខ: ០២៣ ៨៨០ ៤៧៤
Tel: 023 880 474
E-Mail: ........................................ លេខ:..........................

## វិក្កយបត្រ

INVOICE

បានទទួលប្រាក់ពីឈ្មោះ....................................................... អក្សរឡាតាំង ...................................................ភេទ................
អាសយដ្ឋាន: ភូមិ/ក្រុម..........................ឃុំ/សង្កាត់............................ស្រុក/ខណ្ឌ.......................រាជធានី/ខេត្ត........................
ទូរស័ព្ទលេខ.................................................................................................................................................
ចំនួនទឹកប្រាក់....................................ជាអក្សរ.........................................................នៅខ្វះចំនួន.......................................
ប្រាក់ដែលបានបង់នេះ សម្រាប់រៀបចំបំពេញបែបបទ និងឯកសារផ្សេងៗទៅធ្វើការដោយស្របច្បាប់នៅប្រទេស.......................។

ថ្ងៃទី.............ខែ.................ឆ្នាំ................

| | | |
|---|---|---|
| គណនេយ្យករ | បេឡាធិកា | អ្នកប្រគល់ប្រាក់ |
| (ហត្ថលេខា) | (ហត្ថលេខា) | (ស្នាមមេដៃស្តាំ) |
| ឈ្មោះ............................ | ឈ្មោះ.............................. | ឈ្មោះ........................... |

សម្គាល់:

១-វិក្កយបត្រនេះមាន៣ ច្បាប់។ ចំនួន១ច្បាប់ សម្រាប់ភ្ជាប់សំណុំរឿង ចំនួន១ច្បាប់ សម្រាប់អ្នកបង់ប្រាក់ និងចំនួន១ច្បាប់ សម្រាប់រក្សាទុក។

២- លេខវិក្កយបត្រ: ចាប់ពីលេខ N....................
មកដល់លេខ N..................

៣-វិក្កយបត្រត្រូវបោះត្រា PAID ដោយមានឈ្មោះក្រុមហ៊ុន។